ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ...៩.៦០...... PC.អក

## សេចក្តីជូនដំណឹង(លើកទី២)
## ស្តីពី

ការផ្គត់ផ្គង់គ្រឿងបន្លាស់ ជូន រោងចក្រអគ្គិសនីខេត្តចំនួន ០៩ (អគ្គិសនី តាកែវ កំពត បន្ទាយមានជ័យ ព្រៃវែង ស្ទឹងត្រែង ស្វាយរៀង ក្រចេះ មណ្ឌលគិរី និង រតនគិរី) នៃ នាយកដ្ឋានផលិតកម្ម (ផែនការឆ្នាំ២០២២).

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជា នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់គ្រឿងបន្លាស់ ជូន រោងចក្រអគ្គិសនីខេត្តចំនួន ០៩ (អគ្គិសនី តាកែវ កំពត បន្ទាយមានជ័យ ព្រៃវែង ស្ទឹងត្រែង ស្វាយរៀង ក្រចេះ មណ្ឌលគិរី និង រតនគិរី) នៃ នាយកដ្ឋានផលិតកម្ម ។

អគ្គិសនីកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដែលមានអាសយដ្ឋានៈ អាគារលេខ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញចាប់ពីថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០២២ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 / 092 652 357 និង Website: www.edc.com.kh ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១៤:០០ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២២ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង ១៥:០០ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២២ ។

ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់បន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលជាឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃសុក្រ ៣រោច ខែពិសាខ ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០២២
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហាង ឡូច**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ